# សេចក្តីស្រឡាញ់នៃព្រះ

ប្រធាន ឡៅថើរ អេស្វ អុជដូហ្វ
ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ

*សេចក្តីស្រឡាញ់គឺជារង្វាស់នៃសេចក្តីជំនឿរបស់យើង និងជាការបំផុសគំនិតចំពោះការគោរពប្រតិបត្តិរបស់យើង ព្រមទាំងជានិយាមដ៏ពិតនៃភាពជាសិស្សរបស់យើងផងដែរ ។*

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺកំពុងបន្តរីកចំរើន និងមានកេរ្តិ៍ឈ្មោះល្បីល្បាញនៅជុំវិញពិភពលោក។ ទោះបីជាមានពួកអ្នកដែលគិតចំពោះសាសនាចក្រ និងសមាជិករបស់ខ្លួននៅក្នុងផ្លូវអវិជ្ជមានក្តី ក៏មានមនុស្សភាគច្រើនបានគិតចំពោះយើងថាជា មនុស្សដែលមានចិត្តស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងចេះជួយគ្នា។ មានមនុស្សមួយចំនួនបានជិតជាប់នឹងរូបភាពដ៏ស្រស់ស្រាយ ហើយស្អាតបាតរបស់អ្នកផ្សព្វផ្សាយសាសនា ក្រុមគ្រួសារដ៏មនោរម្យ និងពួកអ្នកជិតខាងដែលមានភាពស្និទ្ធស្នាល ដែលមិនចេះជក់បារី និងទទួលទានគ្រឿងស្រវឹង។ យើងក៏អាចត្រូវបានគេស្គាល់ថាជា មនុស្សដែលទៅព្រះវិហារម្តងបីម៉ោងនៅរៀងរាល់ថ្ងៃអាទិត្យ ហើយជាកន្លែងដែលមនុស្សគ្រប់គ្នា ហៅគ្នាទៅវិញទៅមកថា បងប្រុស ឬបងស្រី។ ហើយជាទីកន្លែងដែលកុមារទាំងឡាយច្រៀងបទ សម្លេងទឹកហូរ ដើមផ្កានារតី និងកុមារដែលចង់ក្លាយជាពន្លឺព្រះអាទិត្យ ។

បងប្អូនប្រុសស្រីទាំងឡាយ គ្រប់ការណ៍ទាំងអស់ដែលយើងចង់ឱ្យគេទទួលស្គាល់ តើវាពុំមែនជាគុណសម្បត្តិដ៏ប្រសើរបំផុតដែលកំណត់ថាយើង គឺជាសមាជិកសាសនាចក្ររបស់ទ្រង់ និងជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទទេឬអី? ចាប់តាំងពីសន្និសីទទូទៅចុងក្រោយបង្អស់របស់យើងកាលពីប្រាំមួយខែមុន ខ្ញុំបានពិចារណាអំពីសំណួរនេះ និងសំណួរផ្សេងទៀតដែលស្រដៀងគ្នានេះ។ នៅថ្ងៃនេះ ខ្ញុំចង់ចែកចាយ នឹងអ្នករាល់គ្នាពីគំនិត និងអារម្មណ៍មួយចំនួនដែលបានកើតឡើង នៅពេលខ្ញុំពិចារណាចំពោះបញ្ហានេះ។ សំណួរទីមួយគឺ:

## តើយើងអាចប្រែក្លាយជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទបានដោយរបៀបណា?

ព្រះអង្គសង្គ្រោះផ្ទាល់បានប្រទានចម្លើយជាមួយនឹងសេចក្តីប្រកាសដ៏ជ្រាលជ្រៅបែបនេះថា : "បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ" ។1 ចំណុចសំខាន់នៃពាក្យថាជាសិស្សដ៏ពិតម្នាក់គឺជា: អស់អ្នកទាំងឡាយណាដែលទទួលព្រះយេស៊ូវគ្រីស្ទ ហើយដើរតាមទ្រង់ ។2

ប៉ុន្តែការណ៍នេះអាចបង្កើតជាបញ្ហាដល់មនុស្សមួយចំនួន ពីព្រោះមានរឿងជាច្រើនដែល"គួរ"ធ្វើ និង"មិនគួរ"ធ្វើដែលអាចជារឿងដ៏លំបាកមួយចំពោះការគ្រាន់តែគិត និងការគ្រប់គ្រងលើបញ្ហានេះ។ ពេលខ្លះ គោលការណ៍ដ៏ទេវភាពត្រូវបានមនុស្សដែលមានបំណងល្អពន្យល់ហួសពីអ្វីដែលព្រះអម្ចាស់បានបើកសម្តែង---ភាគច្រើនជាមនុស្សដែលមិនបានទទួលការបំផុសគំនិត---ហើយកាន់តែស្មុគស្មាញជាងនេះទៅទៀត គឺការធ្វើឱ្យបាត់បង់ធាតុដើមនៃសេចក្តីពិតដ៏ទេវភាពនេះ តាមរយៈការដាក់បន្ថែមគំនិត និងការពន្យល់របស់មនុស្ស។ គំនិតដ៏ល្អរបស់មនុស្សម្នាក់---ចំពោះអ្វីមួយដែលគាត់គិតថាអាចប្រើការបាន---បានចាក់ឫស ហើយក្លាយទៅជាមានភាពរឹងមាំ ហើយពុំមែនជាការណែនាំនោះទេ ប៉ុន្តែវាគឺជាការរំពឹងទុកទៅវិញ។ ហើយគោលការណ៍ដ៏នៅអស់កល្បជានិច្ចអាចបាត់បង់បន្តិចម្តងៗនៅក្នុងផ្លូវដ៏ស្មុគស្មាញនៃ "គំនិតដ៏ល្អៗទាំងឡាយ" ។

នេះគឺជាការរិះគន់មួយរបស់ព្រះអង្គសង្គ្រោះចំពោះ "ពួកអ្នកជំនាញ" ខាងសាសនាជាមនុស្សដែលចូលចិត្តផ្តោតសំខាន់ទៅលើតែក្រិត្យវិន័យតូចតាច ហើយបដិសេធក្រិត្យវិន័យធំៗ ដែលទ្រង់បានផ្ទាញ់ផ្ទាលនៅជំនាន់របស់ទ្រង់។3

ដូច្នេះ តើយើងអាចផ្តោតយកចិត្តទុកដាក់ទៅលើរឿងធំៗទាំងនេះបានដោយរបៀបណា? តើមានត្រីវិស័យ ជាក់លាក់ណាមួយដែលអាចជួយយើងដាក់អាទិភាពលើជីវិត គំនិត និងសកម្មភាពយើងបានដែរឬទេ?

ព្រះអង្គសង្គ្រោះបានបើកសម្តែងផ្លូវនេះជាថ្មីម្តងទៀត។ នៅពេលទ្រង់ត្រូវបានគេទូលសួរឱ្យរៀបរាប់ឈ្មោះព្រះបញ្ញត្តិ ដ៏ធំជាងគេដោយគ្មានការស្ទាក់ស្ទើរនោះទ្រង់បានមានបន្ទូលថា : "ត្រូវស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឱ្យអស់ពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង។ នេះជាបញ្ញត្តិយ៉ាងសំខាន់ទីមួយ"។4 ដោយរួមផ្សំ ជាមួយនឹងព្រះបញ្ញត្តិធំទីពីរ ឱ្យស្រឡាញ់អ្នកជិតខាងរបស់យើងដូចជាខ្លួនឯង5---នោះយើងនឹងមានត្រីវិស័យមួយដើម្បីដឹកនាំផ្លូវជីវិតរបស់យើង និងសាសនាចក្ររបស់ព្រះអម្ចាស់ទាំងនៅក្នុងជីវិតនេះ និងជីវិតក្រោយផងដែរ។

ដោយសារសេចក្តីស្រឡាញ់ គឺជាព្រះបញ្ញត្តិដ៏ធំ នោះវាបានក្លាយទៅជាផ្នែកមួយ*ដ៏សំខាន់* នៅក្នុងគ្រប់កិច្ចការទាំងអស់ដែលយើងធ្វើនៅក្នុងគ្រួសាររបស់យើងក្នុងការហៅបំរើរបស់សាសនាចក្រ និងក្នុងជីវិតរស់នៅរបស់យើង។ សេចក្តីស្រឡាញ់ គឺជាថ្នាំព្យាបាលដែលជួយបំបាត់ការឈឺចាប់នៅក្នុងទំនាក់ទំនងផ្ទាល់ខ្លួន និងគ្រួសារ។ វាគឺជាចំណង ដែលបង្រួបបង្រួមគ្រួសារ សហគមន៍ និងប្រទេសជាតិ។ សេចក្តីស្រឡាញ់ គឺជាអំណាចដែលបង្កើតឱ្យមានមិត្តភាព ការអត់ឱន សេចក្តីគួរសម និងគារវភាព។ វាគឺជាប្រភពដើម្បីយកឈ្នះលើការបែកបាក់ និងការស្អប់ខ្ពើមគ្នា។ សេចក្តីស្រឡាញ់ គឺជាភ្លើងដែលធ្វើឱ្យជីវិតរបស់យើងមាន ភាពកក់ក្តៅ ជាមួយនឹងសេចក្តីអំណរដែលមិនអាចប្រៀបផ្ទឹមបាន និងសេចក្តីសង្ឃឹមដ៏ទេវភាព។ យើងគួរតែធ្វើទង្វើរ និងនិយាយស្តីចេញទៅដោយសេចក្តីស្រឡាញ់។

នៅពេលយើងយល់ច្បាស់ថា សេចក្តីស្រឡាញ់ដូចដែលព្រះយេស៊ូវគ្រីស្ទយើងមានអត្ថន័យយ៉ាងណា នោះការភ័ន្តច្រឡំនឹងរសាយបាត់ទៅ ហើយយើងនឹងចាប់ផ្តើមខិតទៅរកព្រះទ័យរបស់ព្រះ។ ជីវិតរបស់យើងក្នុងនាមជាសិស្សរបស់ព្រះគ្រីស្ទកាន់តែមានភាពរីករាយ។ យើងនឹងមានជីវិតថ្មី។ ទំនាក់ទំនងរបស់យើងជាមួយនឹងព្រះវរបិតាសួគ៌ នឹងកាន់តែមានអស្ចារ្យ។ ការគោរពប្រតិបត្តិប្រែក្លាយទៅជាសេចក្តីអំណរវិញ នឹងពុំមែនជាបន្ទុកនោះឡើយ។

## ហេតុអ្វីបានជាយើងត្រូវស្រឡាញ់ព្រះ?

ព្រះជាព្រះដ៏នៅអស់កល្បជានិច្ចមិនបានប្រទានព្រះបញ្ញត្តិដ៏ធំទីមួយនោះ ដោយសារតែទ្រង់សព្វព្រះទ័យឱ្យយើងស្រឡាញ់ទ្រង់នោះទេ។ ព្រះចេស្តា និងសិរីល្អរបស់ទ្រង់នឹងពុំមានការថយចុះឡើយ បើទោះបីជាយើងមិនយកចិត្តទុកដាក់ បដិសេធ ឬធ្វើឱ្យខូច ដល់ព្រះនាមរបស់ទ្រង់ក៏ដោយ។ ឥទ្ធិពល និងការគ្រប់គ្រងរបស់ទ្រង់ពង្រីកនៅពេលគ្រប់ពេល និងគ្រប់ទីកន្លែង ដោយមិន អាស្រ័យទៅលើការទទួលយក ការអនុមតិ ឬការកោតសរសើររបស់យើងនោះទេ។

ព្រះមិនចាំបាច់ឱ្យយើងស្រឡាញ់ទ្រង់នោះទេ។ អូ តែយើងត្រូវស្រឡាញ់ព្រះតាមរបៀបណាទៅ!

ត្បិតអ្វីដែលយើងស្រឡាញ់កំណត់ពីអ្វីដែលយើងស្វះស្វែងរក ។

អ្វីដែលយើងស្វះស្វែងរកកំណត់ពីអ្វីដែលយើងគិត និងធ្វើ ។

អ្វីដែលយើងគិត និងធ្វើកំណត់ពីបុគ្គលិកលក្ខណៈរបស់យើង---និងបុគ្គលដែលយើងចង់ប្រែក្លាយទៅជា នាពេលអនាគត ។

យើងត្រូវបានបង្កើតឡើងតាមរូបភាពនៃព្រះមាតាបិតាសួគ៌របស់យើង ។ យើងគឺជាកូនចៅវិញ្ញាណរបស់ព្រះ ។ ហេតុដូច្នេះហើយ យើងមានសមត្ថភាពដ៏ធំធេងដើម្បីស្រឡាញ់---វាគឺជាផ្នែកមួយនៃកេរមរតកខាងវិញ្ញាណ របស់យើង ។ អ្វីដែលយើងស្រឡាញ់ និងរបៀបដែលយើងស្រឡាញ់មិនគ្រាន់តែកំណត់យើងជាលក្ខណៈបុគ្គលនោះទេ ប៉ុន្តែវាក៏កំណត់យើងជាលក្ខណៈសាសនាចក្រផង ដែរ ។ សេចក្តីស្រឡាញ់ គឺជាការកំណត់នូវឥរិយាបថក្នុងភាពជាសិស្សរបសព្រះគ្រីស្ទ ។

ចាប់តាំងពីដើមដំបូងមកម្ល៉េះ សេចក្តីស្រឡាញ់បានក្លាយជាប្រភពនៃសុភមង្គលដ៏ធំធេង និងជាបន្ទុកដ៏ធ្ងន់បំផុតផងដែរ ។ ចាប់តាំងពីជំនាន់របស់លោកអ័ដាមរហូតមកដល់សព្វថ្ងៃនេះ អ្នករាល់គ្នានឹងរកឃើញថា បុព្វហេតុដ៏ សំខាន់នៃសេចក្តីទុក្ខវេទនា ជាញឹកញាប់ គឺជាសេចក្តីស្រឡាញ់ចំពោះរឿងដែលខុសឆ្គង ។ ហើយឯបុព្វហេតុដ៏សំខាន់នៃសេចក្តីអំណរ នោះអ្នករាល់គ្នានឹងរកឃើញសេចក្តី ស្រឡាញ់ចំពោះរឿងដែលល្អៗ ។

ហើយរាល់វត្ថុដែលល្អជាងគេបំផុតនោះ គឺព្រះ ។

ព្រះវរបិតាសួគ៌របស់យើងដែលគង់នៅស្ថានសួគ៌បានប្រទានឱ្យយើង ដែលជាកូនចៅរបស់ទ្រង់នូវសមត្ថភាពជាច្រើន ដែលយើង មិនអាចដឹងឱ្យអស់សេចក្តីបានឡើយ ។ នៅក្រោមការដឹកនាំរបស់ទ្រង់ ព្រះយេហូវ៉ាដ៏មហិមាបានបង្កើត ពិភពលោកដ៏ស្រស់បំព្រង ដែលយើងកំពុងរស់នៅ ។ ព្រះជាព្រះវរបិតាបានឃុំគ្រងយើង ទ្រង់ធ្វើឱ្យដួងចិត្តរបស់យើង ពេញដោយសេចក្តីអំណរដែលមិនអាច ថ្លែងប្រាប់បាន ទ្រង់បានបំភ្លឺយើងនៅក្នុងគ្រាដ៏ងងឹតជាមួយពរជ័យនៃសេចក្តីសុខសាន្ត ទ្រង់តុបតែងគំនិតរបស់យើងជាមួយនឹង សេចក្តីពិតដ៏មានតម្លៃ ទ្រង់ដឹកនាំយើងឆ្លងកាត់គ្រានៃទុក្ខវេទនា ទ្រង់មានព្រះទ័យរីករាយនៅពេលឃើញយើងរីករាយ ហើយទ្រង់ ឆ្លើយតបចំពោះការទូលសុំដ៏សុចរិតរបស់យើង ។

ទ្រង់បានប្រទានការសន្យាចំពោះជីវិតដ៏រុងរឿង និងគ្មានទីបញ្ចប់ដល់កូនចៅរបស់ទ្រង់ ហើយបានប្រទានផ្លូវមួយឱ្យយើង ដើម្បី រីកចំរើននៅក្នុងចំណេះដឹង និងសីរីល្អ រហូតដល់យើងទទួលបានសេចក្តីអំណរដ៏ពោរពេញ ។ ទ្រង់បានសន្យានឹងប្រទានឱ្យយើងនូវ អ្វីៗទាំងអស់ដែលទ្រង់មាន ។

បើអ្វីៗទាំងអស់នេះមិនទាន់ជាហេតុផលគ្រប់គ្រាន់ នៅក្នុងការស្រឡាញ់ព្រះវរបិតាសួគ៌ទៀត នោះប្រហែលយើងអាចរៀនសូត្រពី ពាក្យសម្តីរបស់សាវកយ៉ូហាន ដែលគាត់បានលើកឡើងថា : "ឯយើងរាល់គ្នា យើងស្រឡាញ់ទ្រង់ ពីព្រោះទ្រង់បានស្រឡាញ់ យើងជាមុន" ។6

**ហេតុអ្វីបានជាព្រះវរបិតសួគ៌ស្រឡាញ់យើង?**

សូមពិចារណាពីសេចក្ដីស្រឡាញ់បរិសុទ្ធដ៏លើសលុប ហើយមានភាពរឹងមាំបំផុតដែលអ្នករាល់គ្នាអាចស្រមើស្រម៉ៃឃើញ។ ឥឡូវនេះ សូមបង្កើនសេចក្ដីស្រឡាញ់នេះឱ្យចំនួនមួយដែលមិនអាចកំណត់បាន នោះហើយគឺជាទំហំនៃសេចក្ដីស្រឡាញ់របស់ព្រះចំពោះយើង។7

ព្រះមិនបានទតមើលមនុស្សតែសំបកក្រៅនេះទេ។8 ខ្ញុំជឿជាក់ថា ទោះជាយើងរស់នៅក្នុងវិមាន ឬផ្ទះដ៏តូច ទោះជាយើងមានរូបរាងសង្ហារ ឬមិនស្រស់ស្អាត ទោះបីជាយើងជាមនុស្សល្បីឈ្មោះ ឬគ្មានកេរ្ដិ៍ឈ្មោះក្ដី ក៏ទ្រង់ពុំមានព្រះទ័យខ្វល់ខ្វាយអ្វីបន្តិចសោះឡើយពីរឿងទាំងហ្នឹង។ ទោះជាយើងពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្ដី ក៏ព្រះស្រឡាញ់យើងដោយពីព្រះទ័យរបស់ទ្រង់ដែរ។ ទោះជាយើង មិនបានល្អឥតខ្ចោះ ក៏ព្រះស្រឡាញ់យើងយ៉ាងល្អឥតខ្ចោះដែរ។ ទោះជាយើងមានអារម្មណ៍ថាវង្វេងផ្លូវ ហើយគ្មានត្រីវិស័យ នាំផ្លូវក្ដីក៏សេចក្ដីស្រឡាញ់របស់ព្រះស្ថិតនៅជុំវិញខ្លួនយើងទាំងស្រុងដែរ។

ទ្រង់ស្រឡាញ់យើង ដោយសារតែទ្រង់ពោរពេញដោយទំហំនៃសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធ ហើយធំធេងបំផុតដែលគ្មានថ្ងៃនឹងបញ្ចប់ឡើយ។ យើងគឺជាមនុស្សសំខាន់ចំពោះព្រះ ពុំមែនដោយសារតែប្រវត្តិរូបរបស់យើងនោះ ប៉ុន្តែដោយសារយើងគឺជាកូនចៅរបស់ទ្រង់។ ទ្រង់ស្រឡាញ់យើងគ្រប់ៗគ្នា សូម្បីតែពួកអ្នកដែលមានកំហុស ពួកអ្នកដែលបោះបង់ចោល ពួកឆោតល្ងង់ ពួកអ្នករងទុក្ខ ឬខូចចិត្តផងដែរ។ សេចក្ដីស្រឡាញ់របស់ព្រះ គឺមានភាពធំធេងណាស់រហូតដល់ទ្រង់ នៅស្រឡាញ់សូម្បីតែជាមនុស្សអំនួត អាត្មានិយម អួតអាង និងមនុស្សទុច្ចរិតក្ដី។

នេះគឺមានន័យថា ទោះជាស្ថានភាពបច្ចុប្បន្នរបស់យើងបែបណាក្ដី គឺយើងនៅតែមានសេចក្ដីសង្ឃឹមជានិច្ច។ មិនថាយើងមានការឈឺចាប់ ទុក្ខសោក ឬមានកំហុសដល់កំរិតណានោះទេ ក៏ព្រះវរបិតាសួគ៌យើងដែលពោរពេញដោយព្រះទ័យមេត្តាករុណាគ្មានទីបញ្ចប់ មានព្រះរាជបំណងចង់ឱ្យយើងចូលមកជិតទ្រង់ ដើម្បីឱ្យទ្រង់អាចខិតទៅជិតយើងវិញផងដែរ។9

**តើយើងអាចបង្កើនសេចក្ដីស្រឡាញ់របស់យើងចំពោះព្រះតាមរបៀបណា?**

ដោយសារ "ព្រះទ្រង់ជាសេចក្ដីស្រឡាញ់"10 កាលណាយើងខិតចូលទៅរកទ្រង់កាន់តែជិត នោះយើងនឹងទទួលបទពិសោធន៍ពីសេចក្ដីស្រឡាញ់កាន់តែច្រើន។11 តែដោយសារតែមានវាំងននមួយនៅខណ្ឌចំកណ្ដាលរវាងជីវិតរមែងស្លាប់នេះ និងគេហដ្ឋានសួគ៌ារបស់យើងនោះយើងត្រូវតែស្វែងរកដោយព្រះវិញ្ញាណចំពោះអ្វីដែលលាក់កំបាំង ពីជីវិតរមែងស្លាប់នេះ។

ពេលខ្លះ ស្ថានសួគ៌មើលទៅហាក់ដូចជានៅឆ្ងាយខ្លាំងណាស់ ប៉ុន្តែព្រះគម្ពីរបានផ្ដល់នូវសេចក្ដីសង្ឃឹមថា : "ឯងរាល់គ្នានឹងស្វែងរកយើង ហើយនឹងឃើញផងគឺកាលណាឯងស្វែងរកយើងឱ្យអស់អំពីចិត្ត "។12

ទោះជាយ៉ាងណាក្ដី ការស្វែងរកព្រះដោយអស់ពីដួងចិត្តរបស់យើង គឺមានន័យច្រើនជាងការអធិស្ឋាន ឬការពោលពាក្យដ៏សាមញ្ញតែពីរបីម៉ាត់ ដើម្បីអញ្ជើញព្រះឱ្យទ្រង់គង់នៅក្នុងជីវិតរបស់យើងទៅទៀត។ "ត្បិតនេះហើយជាសេចក្ដីស្រឡាញ់ដល់ព្រះ គឺឱ្យយើងកាន់តាមអស់ទាំងបញ្ញត្តិរបស់ទ្រង់"។13 យើងអាចបង្កើតការសម្ដែងដ៏អស្ចារ្យមួយ ដោយនិយាយថាយើងស្គាល់ព្រះ ហើយយើងអាចប្រកាសជាសាធារណៈថា យើងស្រឡាញ់ទ្រង់ក៏ពិតមែន។ ប៉ុន្តែ បើ យើងមិនគោរពទ្រង់ នោះរាល់កិច្ចការទាំងអស់នឹង

រាប់ជាអសារបង់វិញ ត្បិត "អ្នកណាដែលថា បានស្គាល់ទ្រង់តែមិនកាន់ តាមបញ្ញត្តិទ្រង់ទេ អ្នកនោះឈ្មោះថាជាអ្នកកុហក ហើយសេចក្ដីពិតមិននៅក្នុងអ្នកនោះឡើយ" ។14

យើងបង្កើនសេចក្ដីស្រឡាញ់របស់យើងចំពោះព្រះវរបិតាសួគ៌ ហើយបង្ហាញសេចក្ដីស្រឡាញ់នោះ តាមរយៈការធ្វើឱ្យគំនិត និងទង្វើរបស់យើងបានសមស្របទៅនឹងព្រះបន្ទូលរបស់ព្រះ ។ សេចក្ដីស្រឡាញ់ដ៏បរិសុទ្ធរបស់ទ្រង់នឹងដឹកនាំ ហើយលើកទឹកចិត្តយើងឱ្យក្លាយខ្លួនជាមនុស្សបរិសុទ្ធជាប់ជានិច្ច ។ សេចក្ដីស្រឡាញ់នេះនឹងបំផុសគំនិតយើងឱ្យដើរ នៅក្នុងសេចក្ដីសុចរិត---ពុំមែនកើតចេញពីសេចក្ដីភ័យខ្លាច ឬជាកាតព្វកិច្ចនោះទេ ប៉ុន្តែចេញពីបំណងប្រាថ្នាដ៏ស្មោះត្រង់ ដើម្បីប្រែក្លាយដូចជាទ្រង់ដោយសារយើងស្រឡាញ់ទ្រង់ ។ ដោយធ្វើបែបនេះ នោះយើងអាច "បានកើតម្ដងទៀត [ហើយ] ...ត្រូវបានសំអាត ដោយសារឈាមគឺជាព្រះលោហិតនៃព្រះរាជបុត្រាបង្កើតតែមួយយ៉ាងនោះដែរ ប្រយោជន៍ឱ្យ [យើង] អាចបានញែកជាបរិសុទ្ធចេញពីអស់ទាំងអំពើបាប ហើយមានសេចក្ដីអំណរចំពោះព្រះបន្ទូល អំពីជីវិតដ៏នៅអស់កល្ប ជានិច្ចនៅនាលោកិយនេះ និងជីវិតនៅអស់កល្បជានិច្ច នៅឯនាបរលោកគឺជាសិរីល្អដ៏នៅអមតៈ" ។15

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ ចូរកុំបាក់ទឹកចិត្តឡើយ បើអ្នករាល់គ្នាបានដើរជំពប់ជើងនៅពេលខ្លះនោះ ។ ចូរកុំមានអារម្មណ៍សោកសៅ ឬអស់សង្ឃឹមឡើយ បើអ្នករាល់គ្នាពុំមានអារម្មណ៍ថាសក្ដិសម ដើម្បីធ្វើជាសិស្សរបស់ព្រះគ្រីស្ទនៅគ្រប់ពេលវេលានោះ ។ ជំហានទីមួយ ដើម្បីដើរនៅក្នុងសេចក្ដីសុចរិត គឺជាការព្យាយាមដ៏សាមញ្ញមួយ ។ យើងត្រូវ *ព្យាយាម* ជឿ ។ សូមព្យាយាមរៀនពីព្រះ---ដោយអានព្រះគម្ពីរ សិក្សាពីពាក្យសម្ដីនៃពួកព្យាការីថ្ងៃចុងក្រោយរបស់យើង ។ សូមជ្រើសរើសស្ដាប់តាមព្រះវរបិតា និងធ្វើ កិច្ចការដែលព្រះបានដាក់ឱ្យយើងធ្វើ ។ សូមព្យាយាម ហើយបន្តព្យាយាមថែមទៀតរហូតដល់កិច្ចការដែលមើលទៅមានការលំបាក អាចនឹងសំរេចទៅបាន--- និងកិច្ចការដែលមើលទៅអាចនឹងប្រព្រឹត្តទៅបានឱ្យក្លាយទៅជាទម្លាប់ និងជាផ្នែកដ៏ពិតនៅក្នុងជីវិតរបស់អ្នក ។

**តើយើងអាចស្ដាប់ឮព្រះសូរសៀងរបស់ព្រះវរបិតាបានដោយរបៀបណា?**

នៅពេលអ្នករាល់គ្នាងាកទៅរកព្រះវរបិតាសួគ៌របស់អ្នក នោះពេលអ្នករាល់គ្នាអធិស្ឋានទៅកាន់ទ្រង់ នៅក្នុងព្រះនាមនៃព្រះគ្រីស្ទ នោះទ្រង់នឹងឆ្លើយតបមកកាន់អ្នករាល់គ្នាវិញ ។ ទ្រង់មានបន្ទូលមកកាន់ យើងនៅគ្រប់ទីកន្លែងទាំងអស់ ។

នៅពេលអ្នករាល់គ្នាអានព្រះបន្ទូលរបស់ព្រះ ដែលបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរ សូមស្ដាប់រកព្រះសូរសៀងរបស់ទ្រង់ ។ នៅក្នុងសន្និសីទទូទៅនេះ និងសន្និសីទលើកក្រោយទៀត នៅពេលអ្នករាល់គ្នាសិក្សាពីពាក្យសម្ដីដែលបានលើកឡើងនៅទីនេះ សូមស្ដាប់រកព្រះសូរសៀងរបស់ទ្រង់ ។

នៅពេលអ្នករាល់គ្នាទៅកាន់ព្រះវិហារបរិសុទ្ធ និងចូលរួមនៅក្នុងការប្រជុំសាសនាចក្រ សូមស្ដាប់រកព្រះសូរសៀងរបស់ទ្រង់ ។ សូមស្ដាប់រកព្រះសូរសៀងរបស់ព្រះវរបិតានៅក្នុងធម្មជាតិដ៏ស្រស់បំព្រង និងបរិបូរ និងនៅក្នុងការខ្សឹបប្រាប់ពីព្រះវិញ្ញាណ ។

នៅក្នុងការប្រាស្រ័យទាក់ទងប្រចាំថ្ងៃរបស់អ្នកជាមួយនឹងអ្នកដទៃ នៅក្នុងទំនុកច្រៀងនៃទំនុកដំកើង នៅក្នុងចំណើចរបស់កុមារតូចម្នាក់ នោះសូមស្ដាប់រកព្រះសូរសៀងរបស់ទ្រង់ ។

បើអ្នករាល់គ្នាស្ដាប់នូវព្រះបន្ទូលរបស់ព្រះវរបិតា នោះទ្រង់នឹងដឹកនាំអ្នករាល់គ្នាឱ្យដើរលើផ្លូវ ដែលនឹងអនុញ្ញាតឱ្យអ្នករាល់គ្នាជួបប្រទះនឹងសេចក្ដីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ ។

នៅពេលយើងខិតចូលជិតព្រះវរបិតាសួគ៌ នោះយើងនឹងមានចិត្តបរិសុទ្ធកាន់តែច្រើនឡើង ។ ហើយនៅពេលយើងកាន់តែមានភាពបរិសុទ្ធច្រើនឡើង នោះយើងនឹងយកឈ្នះលើការឥតជំនឿ ហើយព្រលឹងរបស់យើងនឹងពោរពេញដោយពន្លឺរបស់ទ្រង់ ។ នៅពេលយើងរៀបចំជីវិតរបស់យើងឱ្យស្របតាមពន្លឺដ៏អស្ចារ្យនេះ នោះវានឹងដឹកនាំ យើងចេញពីសេចក្ដីងងឹត ហើយឆ្ពោះទៅរកពន្លឺដ៏រុងរឿងថែមទៀត ។ ពន្លឺដ៏រុងរឿងនេះនឹងដឹកនាំយើងទៅរកការបំរើដែលមិនអាចពិពណ៌នាបានពីសំណាក់ព្រះវិញ្ញាណបរិសុទ្ធ ហើយវាំងននដែលខណ្ឌចែកស្ថានសួគ៌ ហើយនឹងផែនដី នឹងកាន់តែមានភាពស្ដើងទៅៗ ។

## ហេតុអ្វីបានជាសេចក្ដីស្រឡាញ់ គឺជាព្រះបញ្ញត្តិដ៏ធំ?

សេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ចំពោះកូនចៅរបស់ទ្រង់ គឺជាសារលិខិតដ៏សំខាន់មួយក្នុងផែនការនៃសុភមង្គល ជាផែនការមួយអាចដំណើរការទៅបាន តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ---ជាការសម្ដែងចេញពីសេចក្ដីស្រឡាញ់ដ៏ធំធេងបំផុត ដែលនៅក្នុងពិភពលោកនេះពុំធ្លាប់មានពីមុនមក ។ 16

នៅពេលព្រះអង្គសង្គ្រោះមានបន្ទូលថា រាល់ព្រះបញ្ញត្តិផ្សេងទៀតគឺពឹងផ្អែកទៅលើគោលការណ៍នៃសេចក្ដីស្រឡាញ់ នោះទ្រង់មានបន្ទូលយ៉ាងច្បាស់លាស់អ្វីម្ល៉េះទេ ។ បើយើងមិនបដិសេធចំពោះក្រិត្យវិន័យដ៏ធំនេះទេ---ហើយបើយើងពិត ជារៀនស្រឡាញ់ព្រះវរបិតាយើង និងបងប្អូនរបស់យើងដោយអស់ពីដួងចិត្ត ពីព្រលឹង ពីគំនិតរបស់យើងមែន---នោះរឿងជាច្រើនផ្សេងទៀតនឹងកើតមានឡើងស្របទៅតាមសភាពធម្មតា ។

សេចក្ដីស្រឡាញ់ដ៏ទេវភាពរបស់ព្រះបានបង្វែរទង្វើរដ៏សាមញ្ញ ទៅជាការបំរើដ៏អស្ចារ្យ ។ សេចក្ដីស្រឡាញ់ដ៏ទេវភាព គឺជាការលើកទឹកចិត្តដែលកែប្រែពីពាក្យដ៏សាមញ្ញឱ្យទៅជាព្រះគម្ពីរដ៏ពិសិដ្ឋ ។ សេចក្ដីស្រឡាញ់ដ៏ទេវភាព គឺជាកត្តាដែលប្រែក្លាយ ការត្អូញត្អែរចំពោះព្រះបញ្ញត្តិរបស់ព្រះ ឱ្យទៅជាការលះបង់ និងការពលិកម្មដ៏បរិសុទ្ធ ។

សេចក្ដីស្រឡាញ់គឺជាពន្លឺដឹកនាំផ្លូវដែលបំភ្លឺផ្លូវនៃភាពជាសិស្ស ហើយបំពេញដំណើរជីវិតប្រចាំថ្ងៃរបស់យើងឱ្យមានអត្ថន័យ និងភាពអស្ចារ្យ ។

សេចក្ដីស្រឡាញ់គឺជារង្វាស់នៃសេចក្ដីជំនឿរបស់យើង និងជាការបំផុសគំនិតចំពោះការគោរពប្រតិបត្តិរបស់យើង ព្រមទាំងជាឥរិយាបថដ៏ពិតនៃភាពជាសិស្សរបស់យើងផងដែរ ។

សេចក្ដីស្រឡាញ់គឺជាផ្លូវនៃភាពជាសិស្ស ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះគង់នៅស្ថានសួគ៌។ ទ្រង់មានព្រះជន្មរស់។ ទ្រង់ស្គាល់ និងស្រឡាញ់អ្នករាល់គ្នា។ ទ្រង់មានព្រះទ័យខ្វល់ខ្វាយពីអ្នក។ ទ្រង់ស្ដាប់ដល់ការអធិស្ឋានរបស់អ្នក ហើយយល់ពីបំណងប្រាថ្នានៅក្នុងដួងចិត្តរបស់អ្នក។ សេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះអ្នករាល់គ្នាគឺគ្មានទីបញ្ចប់ឡើយ។

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ ខ្ញុំសូមបញ្ចប់ដោយលើកយកចំនុចដែលខ្ញុំបានចាប់ផ្ដើមថា: តើគិរិយាបទបែបណាដែលអាចកំណត់យើងថា ជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយបាននោះ?

ចូរយើងធ្វើឱ្យអ្នកដទៃស្គាល់ថា យើងគឺជាមនុស្សដែលស្រឡាញ់ព្រះដោយអស់ពីដួងចិត្ត ពីព្រលឹង និងជាមនុស្សស្រឡាញ់អ្នកជិតខាងរបស់យើង ដូចជាខ្លួនឯងផងដែរ។ ពេលយើងយល់ ហើយអនុវត្តនូវព្រះបញ្ញត្តិដ៏ធំទាំងពីរនេះនៅក្នុងក្រុមគ្រួសារ នៅក្នុងវួដ និងសាខា នៅក្នុងប្រទេសជាតិ នៅក្នុងសហគមន៍ និងនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង នោះយើងនឹងចាប់ផ្ដើមយល់នូវអត្ថន័យដ៏ពិតនៃភាពជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ។ ខ្ញុំសូមថ្លែងទីបន្ទាល់ពីកិច្ចការនេះ នៅក្នុងព្រះនាមដ៏ពិសិដ្ឋនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. យ៉ូហាន 14:15 ។
2. សូមមើល កូល៉ុស 2:6 ។
3. សូមមើល ម៉ាថាយ 23:23 ។
4. ម៉ាថាយ 22:37, 38 ។
5. សូមមើល ម៉ាថាយ 22:39 ។
6. យ៉ូហានទី 1 4:19 ។
7. សូមមើល អេសាយ 54:10 យេរេមា 31:3 ។
8. សូមមើល សាំយ៉ូអែលទី 1 16:7 ។
9. សូមមើល គ. និង ស. 88:63 ។
10. យ៉ូហានទី 1 4:8 ។
11. សូមមើល រ៉ូម 5:5 យ៉ូហានទី 1 4:7, 16 ។
12. យេរេមា 29:13 ។
13. យ៉ូហានទី 1 5:3 សូមមើល យ៉ូហានទី 2 1:6 ផងដែរ។
14. យ៉ូហានទី 1 2:4 សូមមើលផងដែរ អេសាយ 29:13 ។
15. ម៉ូសេ 6:59 ។
16. សូមមើល យ៉ូហាន 15:13 ។
17. សូមមើល ម៉ាថាយ 22:40 ។